ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ៤១/០៩- អេ អេស ឌី**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៧នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **អន ណាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន អេ អេស ឌី (ខេមបូឌា) ខូ អិលធីឌី**

អាសយដ្ឋាន : ផ្លូវជាតិលេខ៤ ភូមិកន្ទោកខាងជើង ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩២៨ ៩៦៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

- លោក ពៅ អារុណ ប្រធានរដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា-សហជីពសម្លេងកម្មករកម្ពុជាក្រុមហ៊ុន អេ អេស ឌី (CFWU-ASD)**

អាសយដ្ឋាន : ផ្លូវលំ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០៩២ ៧៧ ៦៨ ៦២ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ផន ម៉ៃ ប្រធានសហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា

២- លោក សុខ វុទ្ធី ប្រធានសហជីពសម្លេងកម្មករកម្ពុជានៃក្រុមហ៊ុន ASD

៣- លោក តៃ ណាំ អគ្គលេខាសហជីពសម្លេងកម្មករកម្ពុជានៃក្រុមហ៊ុន ASD

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ក្រុមហ៊ុនឯកភាពណែនាំអប់រំដោយផ្ទាល់មាត់ដល់ប្រធានផលិតកម្ម កុំឱ្យស្រែកគំរាម ឬ ប្រើអាកប្បកិរិយាមិនសមរម្យមកលើកម្មករនៅពេលកំពុងធ្វើការងារ។ ភាគីកម្មករមិនឯកភាពចំពោះការណែនាំ អប់រំដោយផ្ទាល់មាត់ តែសូមឱ្យក្រុមហ៊ុនធ្វើការណែនាំអប់រំដោយលិខិតលាយលក្ខណ៍អក្សរ។

២- ភាគីកម្មករសុំឱ្យក្រុមហ៊ុនបញ្ឈប់ការគំរាមកំហែងចំពោះកម្មករដែលមានប្រាក់ជំនាញ និងបិទសិទ្ធិសេរីភាពរបស់ពួកគេ។ ភាគីក្រុមហ៊ុនបញ្ជាក់ថា ចំពោះបញ្ហានេះបានដោះស្រាយរួចរាល់ហើយ ចំពោះលោក ឆែ ណាំ ជាករណីដោយឡែក។

៣-ភាគីកម្មករសុំឱ្យក្រុមហ៊ុនកាត់បន្ថយចំនួនកំណត់ ដែលក្រុមហ៊ុនបានដាក់ឱ្យកម្មករធ្វើឱ្យសមាមាត្រទៅរយៈពេល៨ម៉ោង ហើយនៅពេលកម្មករធ្វើបានតាមចំនួនកំណត់របស់ក្រុមហ៊ុន ត្រូវអនុញ្ញាតឱ្យកម្មករបានឈប់សម្រាក។ ភាគីក្រុមហ៊ុនសូមអនុវត្តដូចពេលកន្លងមក។

៤-ក្រុមហ៊ុនត្រូវពិនិត្យមើលបំពង់ផ្សែង ប៊ុយ ឡឺ និងផេះ ដែលប៉ះពាល់ដល់កម្មករនៅពេលកំពុងធ្វើការងារ និងពិនិត្យមើលកន្លែងហូបបាយរបស់កម្មករ ដែលជាប់ទៅនឹងគំនរសំរាម និងបង្គន់។

៥-ក្រុមហ៊ុនត្រូវរៀបចំកន្លែងដាក់ កង់ ម៉ូតូ កុំឱ្យមានទឹកលិច និងភក់។

៦-ក្រុមហ៊ុនត្រូវមានថ្នាំពេទ្យគ្រប់គ្រាន់នៅពេលដែលកម្មករមានជម្ងឺនៅពេលកំពុងធ្វើការងារ។

៧-រាល់ពេលធ្វើការថែមម៉ោងចាប់ពីម៉ោង៦:០០ដល់ម៉ោង៨:៣០យប់ ក្រុមហ៊ុនត្រូវផ្តល់ប្រាក់ថ្លៃបាយឱ្យបានទៀងទាត់តាមការកំណត់។

៨-សូមឱ្យក្រុមហ៊ុនទទួលយកលោក ឆែ ណាំ ដែលជាលេខាសហជីពសម្លេងកម្មករកម្ពុជាចូលធ្វើការវិញ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាស ស្តីពីការតែងតាំង សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១១០/០៩ ក.ប./កណ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៩ ត្រូវបានបញ្ជូន

មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។

**សវនាការ និង សន្ទនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ ( វេលាម៉ោង ០៣:០០ នាទី ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានទទួលបណ្តឹងរបស់សហព័ន្ធសហជីពសម្លេងកម្មករចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការប្តឹងនាយកក្រុមហ៊ុន អេ អេស ឌី ដោយមូលហេតុមិនព្រមធ្វើការពិភាក្សាជាមួយសហជីព។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ ដោយបានទទួលលទ្ធផលសះជាចំនួន០១ចំណុចលើការទាមទារចំនួន០៩ចំណុច។ ចំណុចមិនសះជាចំនួន០៨ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន០៨ចំណុចនេះ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចវិវាទទាំង ០៨ ចំណុចនេះ ហើយបានទទួលលទ្ធផលសះជាលើចំណុចទី១ ចំណុចទី៤ ចំណុចទី ៥ និងចំណុចទី ៦។ ចំណែកចំណុចទី ២ និងទី ៨ ( ករណីលោក ឆៃ ណាំ) ភាគីកម្មករនិយោជិតឯកភាពបញ្ចូលគ្នា។ ដូច្នេះ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែលើចំណុចវិវាទទី២ និងទី៨ ( ករណីលោក ឆៃ ណាំ) ចំណុចវិវាទទី៣ និងចំណុចវិវាទទី ៧ ប៉ុណ្ណោះ ដោយផ្អែកលើភស្តុតាង និង ហេតុផលដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន អេ អេស ឌី ជូនលោក ពៅ អារុណ និងលោកស្រី ទូច សម្ផស្ស ដើម្បីចូលរួមដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩។

២- លិខិតលេខ ASD-09/01 ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៩ គោរពជូនប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល សំណើសុំព្យួរការងារមេជាងចំនួន១រូបឈ្មោះ រៃ ណាំ ។

៣- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន អេ អេស ឌី ជូនលោក ពៅ អារុណ និងលោកស្រី ទូច សម្ផស្ស ដើម្បីចូលរួមដោះស្រាយវិវាទការងារនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ចុះថ្ងៃទី១២ និងថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩។

៤- កំណត់ហេតុចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីបញ្ហារបស់លោក រៃ ណាំ ។

៥- កំណត់ហេតុផ្សះផ្សាវិវាទការងារបុគ្គល ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩ ។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន អេ អេស ឌី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៨។

៧- វិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន អេ អេស ឌី ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣។

៨- លិខិតលេខ ០៧៥/០៩ កប/កណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ជម្រាបមក ក្រុមហ៊ុន អេ អេស ឌី ស្តីពីការឱ្យក្រុមហ៊ុនទទួលយកលោក រៃ ណាំ ចូលធ្វើការវិញ និងគិតប្រាក់ឈ្នួលរំលឹកឡើងវិញ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសម្លេងកម្មករកម្ពុជាក្រុមហ៊ុន អេ អេស ឌី ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ។

២- លក្ខន្តិកៈសហជីពសម្លេងកម្មករកម្ពុជាក្រុមហ៊ុន អេ អេស ឌី ចុះបញ្ជិកាលេខ ១៥៨៦ កប/វក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ។

៣- លិខិតលេខ ០៧៥/០៩ កប/កណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ជម្រាបមក ក្រុមហ៊ុន អេ អេស ឌី ស្តីពីការឱ្យក្រុមហ៊ុនទទួលយកលោក រៃ ណាំ ចូលធ្វើការវិញ និងគិតប្រាក់ឈ្នួលរំលឹកឡើងវិញ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេ អេស ឌី លេខ ១១០/០៩ ក.ប/កណ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន អេ អេស ឌី ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៧៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៧៧ កប/អក/វក/លកអ. ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៩ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន អេ អេស ឌី មានជួលកម្មករនិយោជិតសរុបចំនួនប្រហែល ៨៥០នាក់ ។
- សហជីពសម្លេងកម្មករ និងសហព័ន្ធសម្លេងកម្មករគឺជាដើមបណ្តឹងនៅក្នុងរឿងនេះ ។

**ក. ចំណុចវិវាទដែលភាគីព្រមព្រៀង :**

**ចំណុចវិវាទទី ១ :** ភាគីកម្មករនិយោជិត និងនិយោជកឯកភាពធ្វើការអប់រំប្រធានផលិតកម្មក៏ដូចជាកម្មករទូទៅដោយវិធីដូចៗគ្នា គឺ អប់រំដំបូងដោយផ្ទាល់មាត់ និង បន្ទាប់មកជាលាយលក្ខណ៍អក្សរ ។

**ចំណុចវិវាទទី ៤ :** ភាគីកម្មករនិយោជិត និងនិយោជកឯកភាពចុះពិនិត្យមើលរួមគ្នា នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០៩ នូវបំពង់ផ្សែងប៊ុយឡឺ និង ផេះ សំរាមដើម្បីរកវិធីកែសម្រួលកុំឱ្យប៉ះពាល់ដល់កម្មករនិយោជិត ។

**ចំណុចវិវាទទី ៥ :** ក្រុមហ៊ុនបានរៀបចំចាក់ថ្មសម្រាប់កន្លែងដាក់កង់ ម៉ូតូរួចហើយ ប៉ុន្តែប្រសិនបើនៅរដូវវស្សាខាងមុខនេះមានភ្លៀងលិចទៀត ក្រុមហ៊ុននឹងពិនិត្យកែសម្រួលបន្ថែម ។

**ចំណុចវិវាទទី ៦ :** ក្រុមហ៊ុនឯកភាពរៀបចំឱ្យមានថ្នាំពេទ្យគ្រប់គ្រាន់ ។

**ខ. ចំណុចមិនសះជាដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដើម្បីចេញសេចក្តីបង្គាប់ :**

**ចំណុចវិវាទទី២ និងចំណុចវិវាទទី៨ : ការទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ឆៃ ណាំ ចូលធ្វើការវិញ និង ការទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការគម្រាមកំហែង និង បិទសិទ្ធិសេរីភាព**

- លោក ឆៃ ណាំ ជាកម្មករនិយោជិតរោងចក្រ អេ អេស ឌី គាត់មាននាទីជាជាងម៉ាស៊ីន ។
- ក្រុមហ៊ុនប្តូរការងារលោក ឆៃ ណាំ ពីកន្លែងរោងជាងទៅកន្លែងថ្មីក្បែរការិយាល័យគណនេយ្យ នៅមុនក្រុមហ៊ុនសម្រេចព្យួរការងារគាត់ ការផ្លាស់ប្តូរនេះដោយសារមូលហេតុថា លោកមិនព្រមធ្វើការងារសកម្មដូចមុន ដោយចាំឱ្យមានអ្នកបញ្ជាទើបធ្វើ ហើយម្យ៉ាងទៀត ព្រោះគណនេយ្យជាអ្នកបើកសំភារៈឱ្យជាងទើបឱ្យទៅនៅក្បែរគណនេយ្យ ។
- លោក ឆៃ ណាំ អះអាងថា លោកចាំឱ្យមានអ្នកបញ្ជាទើបធ្វើ ដោយមូលហេតុថា មិនហ៊ានធ្វើផ្តេសផ្តាសខ្លាច

ខុស ព្រោះគាត់ធ្លាប់ត្រូវក្រុមហ៊ុនចោទប្រកាន់អំពីការចំណាយក្នុងការសង់រោងកន្លងមក ដែលក្រុមហ៊ុនយល់ថា ការចំណាយលើសពាក់កណ្តាល ។

- ក្រុមហ៊ុនបញ្ជាក់ថា ការផ្លាស់ប្តូរការងារគាត់ពីកន្លែងចាស់មកកន្លែងថ្មីនេះមិនប៉ះពាល់ប្រាក់ឈ្នួលគាត់ទេ ហើយក្នុងម៉ោងការងារដដែល ។ ចំណែកចំងាយពីកន្លែងចាស់មកកន្លែងថ្មី គឺ ប្រហែល១០ម៉ែត្រ ។ ចំពោះបញ្ហាជំនាញ វិញនៅតែផ្នែកម៉ាស៊ីនដដែល ។
- ក្រុមហ៊ុនបញ្ជាក់ថា ដោយសារតែគាត់មិនព្រមទៅធ្វើការកន្លែងថ្មីនេះហើយ បានជាក្រុមហ៊ុនសម្រេចព្យួរការងារគាត់នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០៥ ។ ប៉ុន្តែមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាលយល់ថា ក្រុមហ៊ុនបញ្ឈប់លោក នៃ ណាំ ខុស ហើយបានបញ្ជាឱ្យក្រុមហ៊ុនទទួលគាត់ចូលធ្វើការវិញ តាមរយៈលិខិតចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៥ ដែលចែងថា "...លោកនាយកត្រូវទទួលយកលោក នៃ ណាំ ចូលធ្វើការជាធម្មតាវិញ និងត្រូវរំលឹកប្រាក់ឈ្នួលឱ្យផង ។..."
- លោក នៃ ណាំ បដិសេធមិនព្រមទៅធ្វើការកន្លែងថ្មីមូលហេតុកន្លែងថ្មីនេះបិទសិទ្ធិសេរីភាពគាត់មិនឱ្យជួបកម្មករនិយោជិត ព្រោះគាត់ជាលេខាសហជីព ហើយនៅរោងជាងចាស់ គាត់អាចជួបកម្មករនិយោជិត ព្រោះនៅក្បែរកម្មករនិយោជិត ។ ចំណែកឯបញ្ហាចំណាយសង់រោងនោះគាត់ធ្វើតាមបញ្ជាក្រុមហ៊ុនទេ ។
- មកដល់ថ្ងៃសវនាការក្រុមហ៊ុនឯកភាពទទួលយកលោក នៃ ណាំ ចូលធ្វើការវិញដោយឱ្យធ្វើការនៅកន្លែងថ្មីក្បែរការិយាល័យគណនេយ្យ ដែលជាកន្លែងនិយោជកបានផ្លាស់ប្តូរគាត់កន្លងមក ។ ប៉ុន្តែលោក នៃ ណាំ មិនព្រមចូលទៅធ្វើការនៅកន្លែងថ្មីនេះទេ ។ លោក នៃ ណាំ នៅតែទាមទារទៅធ្វើការកន្លែងចាស់ ដែលគាត់ធ្លាប់ធ្វើពីមុន ។
- លោក នៃ ណាំ បានទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការគម្រាមកំហែងដោយហៅប៉ូលីសមកចាប់គាត់ ។ ក្រុមហ៊ុនបានឆ្លើយថា ក្រុមហ៊ុនមិនបានហៅប៉ូលីសមកចាប់គាត់ទេ គឺលោកថៅកែឱ្យហៅប៉ូលីសមកវាស់ដែកសង់រោង ដោយសារអស់ថ្ងៃច្រើនពេក ហើយគ្មានបុគ្គលិកណាម្នាក់ហ៊ានឡើងវាស់ដែកសង់រោងនោះទេ ព្រោះខ្លាចមានបញ្ហាជាមួយលោក នៃ ណាំ ។ ប៉ុន្តែនិយោជកមិនបានហៅប៉ូលីសមកទេ ។
- ភាគីកម្មករនិយោជិតមិនបានបង្ហាញភស្តុតាងណាផ្សេងថា មានការគម្រាមកំហែង ឬបិទសិទ្ធិសេរីភាពទេ ។

**ចំណុចវិវាទទី ៣: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនកំណត់ចំនួនខោអាវឱ្យកម្មករនិយោជិតធ្វើសមាមាត្រចំនួន ៨ ម៉ោង (ម៉ោងការងារ)**

- ការអនុវត្តបច្ចុប្បន្ន ក្រុមហ៊ុនកំណត់ចំនួនខោអាវឱ្យកម្មករនិយោជិតធ្វើជូនកាល៨ម៉ោង ហើយជូនកាលទៀត១០ម៉ោង ទៅ១២ម៉ោង ។ ឧទាហរណ៍ ក្រុមហ៊ុនកំណត់ឱ្យកម្មករនិយោជិតមួយក្រុម ដេរខោអាវឱ្យបាន ១២០០ ក្នុងរយៈពេល១០ម៉ោង ឬ១២ម៉ោង ប្រសិនបើកម្មករនិយោជិតធ្វើហើយនៅម៉ោង០៣

ពួកគេអាចចេញទៅផ្ទះបាន ហើយក្រុមហ៊ុនគិតប្រាក់ឱ្យ១០ម៉ោង ឬ១២ម៉ោង អាស្រ័យតាមការកំណត់របស់ក្រុមហ៊ុន។

- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនកំណត់ត្រឹម៨ម៉ោងវិញ ព្រោះជួនកាលកម្មករនិយោជិតធ្វើមិនហើយ ក៏ត្រូវបង្ខំចិត្តធ្វើការលើស១០ម៉ោង ឬ១២ម៉ោង។ មានន័យថា សុំឱ្យក្រុមហ៊ុនកំណត់ចំនួនសមាមាត្រ៨ម៉ោង (ម៉ោងការងារ) និងចំនួនសម្រាប់ការងារថែមម៉ោងផ្សេង មូលហេតុច្បាប់ការងារចែងថា ម៉ោងការងារ ៨ម៉ោង ហើយថែមម៉ោង២ម៉ោង។ កម្មករនិយោជិតបញ្ជាក់ថា ក្រុមហ៊ុនកំណត់ចំនួនសម្រាប់១០ម៉ោង ឬ១២ម៉ោងស្ទើរតែរាល់ថ្ងៃក្នុងមួយឬក៏។
- ក្រុមហ៊ុនមិនឯកភាពទេព្រោះនេះជាការកំណត់របស់ផ្នែកផលិតកម្ម។

**ចំណុចវិវាទទី ៧: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយសម្រាប់ការថែមម៉ោងពីម៉ោង ៦:០០ ដល់ ម៉ោង ៨:៣០ ឱ្យបានទៀងទាត់រាល់ថ្ងៃ**

- នៅក្រុមហ៊ុន អេ អេស ឌី ម៉ោងការងារធម្មតាគឺ ព្រឹកចូលម៉ោង ៧ ចេញម៉ោង ១១:៣០ ហើយពេលរសៀលចូលម៉ោង ១២:៣០ ចេញម៉ោង ១៦:០០ បើមិនមានការថែមម៉ោង។
- ភាគីទាំងពីរបានបញ្ជាក់ថា ពេលខ្លះថែមម៉ោង២ម៉ោងក្នុងមួយថ្ងៃ គឺចេញនៅម៉ោង១៨:០០ ហើយនិយោជកបានឱ្យប្រាក់ថ្លៃបាយ១០០០រៀលក្នុងពេលធ្វើការថែមម៉ោងម្តង។ ចំពោះប្រាក់ថ្លៃបាយ១០០០រៀលសំរាប់ការថែមម៉ោង២ម៉ោងនេះ និយោជកបានបើកឱ្យជាមួយនិងប្រាក់ខែ ហើយចំណុចនេះមិនមានជំលោះទេ។ តែនៅពេលធ្វើការថែមម៉ោងបន្តទៀតពីម៉ោង១៨:០០ រហូតដល់ម៉ោង២០:៣០ និយោជកបានព្រមព្រៀងឱ្យប្រាក់ថ្លៃបាយបន្ថែម១០០០រៀលទៀត។
- ភាគីសហជីពបញ្ជាក់ថា ចាប់ពីក្រុមហ៊ុនដំណើរការមក ចំពោះប្រាក់បាយសំរាប់ថែមម៉ោងរហូតដល់ម៉ោង ២០:៣០នាទីនេះ និយោជកតែងតែបើកឱ្យជារៀងរាល់ថ្ងៃ តាមរយៈប្រធានក្រុម តែចាប់ពីដើមឆ្នាំ២០០៩ មកការបើកប្រាក់នេះមានការយឺតយ៉ាវ ពេលខ្លះ៣-៤ថ្ងៃ រឺមួយអាទិត្យទើបបើកឱ្យម្តង ហើយពេលខ្លះមានការបាត់ប្រាក់កម្មករទៀតផង។
- ចំពោះភាគីនិយោជកវិញបានបញ្ជាក់ថា ការបើកប្រាក់នោះពិតជាមានការយឺតយ៉ាវមែន តែទោះជាយ៉ាងណាមិនយឺតហួសពី១អាទិត្យទេ។

**ហេតុផលក្នុងការធ្វើសេចក្តីសម្រេច :**

**ក. <u>ចំណុចវិវាទដែលភាគីព្រមព្រៀង:</u> ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនធ្វើការពិចារណាលើចំណុចវិវាទទី ១ ទី ៤ ទី៥ និង ទី ៦ ទេ ព្រោះ ភាគីទាំងពីរបានព្រមព្រៀងគ្នាហើយ។**

## ខ. ចំណុចមិនសះជាដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដើម្បីចេញសេចក្តីបង្គាប់ :

**ចំណុចវិវាទទី២ និងចំណុចវិវាទទី៨: ការទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ផៃ ណាំ ចូលធ្វើការវិញ និង ការទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការគម្រាមកំហែង និង បិទសិទ្ធិសេរីភាព**

ក្នុងករណីនេះ ភាគីសហជីពបានទាមទារឱ្យនិយោជកទទួលយកលោក ផៃ ណាំ ដែលជាលេខាសហជីពឱ្យចូលធ្វើការវិញ។ ពេលសវនាការ ភាគីនិយោជកបានបញ្ជាក់ថា និយោជកឯកភាពទទួលលោក ផៃ ណាំ ឱ្យចូលធ្វើការវិញ ដោយរក្សាមុខតំណែង និងប្រាក់ឈ្នួលនៅដដែល តែនិយោជកតម្រូវឱ្យលោក ផៃ ណាំ ទៅធ្វើការនៅកន្លែងថ្មី នៅជិតគណនេយ្យ គឺឱ្យនៅមួយកន្លែងសម្រាប់ហោង ខ្ចៅ ខ្ចង ម៉ាស៊ីនតែប៉ុណ្ណោះ។ ដូចនេះ មិនមានជំលោះអំពីការទទួលចូលធ្វើការវិញទេ គឺ ជំលោះអំពីការប្តូរកន្លែងការងាររបស់លោក ផៃ ណាំ តែប៉ុណ្ណោះ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើចំណុចវិវាទអំពីទីតាំងកន្លែងធ្វើការនេះ មាននៅក្នុងកំណត់ហេតុមិនសះជា ដែលបញ្ជូនដោយមន្ទីរការងារ ឬជាផលវិបាកផ្ទាល់នៃវិវាទ ឬទេ?

យោងតាមមាត្រា៣១២ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា: " *ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ ។...*"

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតចំពោះចំណុចវិវាទដែលមិនមាននៅក្នុងកំណត់ហេតុមិនសះជាដែលបញ្ជូនដោយអធិការកិច្ចការងារ ឬមិនមែនជាផលវិបាកផ្ទាល់នៃវិវាទ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ១៥៣/០៨-ប៉ោ តិច ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី ១. ២. ៣, លេខ ០៦/០៨-ហ៊ឹង ឡែន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ១៤/០៧- ស៊ូ ព្រីមៀរ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទបន្ថែម, លេខ ៤២/០៧-សៅធនី បេ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ៣ និងលេខ ២៩/០៥- កាង នឹង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៧*) ។

យោងតាមអង្គហេតុ ការផ្លាស់ប្តូរកន្លែងការងាររបស់លោក ផៃ ណាំ នេះមិនមែនជាវិវាទ ដែលកើតក្រោយការធ្វើកំណត់ហេតុមិនសះជានេះទេ គឺជាវិវាទដែលកើតមុនការធ្វើកំណត់ហេតុមិនសះជា។ ដោយសារតែលោក ផៃ ណាំ មិនព្រមផ្លាស់ទៅកន្លែងថ្មី ទើបនិយោជកសម្រេចចិត្តព្យួរការងាររបស់គាត់ពីពេលនោះមក។ ហើយវិវាទអំពីការប្តូរទីកន្លែងការងារនេះ ក៏មិនមាននៅក្នុងកំណត់ហេតុមិនសះជាដែរ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទារឱ្យក្រុមហ៊ុនទទួលយកលោក ផៃ ណាំ ដែលជាលេខាសហជីពសម្លេងកម្មករកម្ពុជាចូលធ្វើការវិញ។

ចំពោះការទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការគម្រាមកំហែង និងបិទសិទ្ធិសេរីភាព ភាគីកម្មករនិយោជិត

មិនបានបង្ហាញភស្តុតាងជាក់លាក់ទេ។ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា ភាគីដែលធ្វើការចោទប្រកាន់មានបន្ទុកបង្ហាញភស្តុតាង។ (សូមមើលសេចក្តីបង្គាប់សំណុំរឿងលេខ *៧៩/០៥-អេវើរគ្រីន.លេខ ៧៧/០៨- ស៊ីង តាយ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១, លេខ ១០១/០៨-ជីឌីអ៊ឹម ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និង ទី២ និងលេខ ១០៨/០៨-ហ៊ូ ហ្គោ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤* ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញា កណ្តាលក្នុងសំណុំរឿងមុនៗដែរ។ ដូច្នេះ ដើម្បីឱ្យស្របនឹងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការគម្រាមកំហែង ចំពោះកម្មករដែលមានប្រាក់ជំនាញ និងបិទសិទ្ធិ សេរីភាពរបស់ពួកគេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាការទាមទារឱ្យក្រុមហ៊ុនទទួលយកលោក នៃ ណាំ ដែលជាលេខាសហជីពសម្លេងកម្មករកម្ពុជាចូលធ្វើការវិញ និងបដិសេធការទាមទារឱ្យក្រុមហ៊ុន បញ្ឈប់ការគម្រាម កំហែងចំពោះកម្មករ ដែលមានប្រាក់ជំនាញ និងបិទសិទ្ធិសេរីភាពរបស់ពួកគេ។

**ចំណុចវិវាទទី ៣ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនកំណត់ចំនួនខោអាវឱ្យកម្មករនិយោជិតធ្វើសមាមាត្រចំនួន ៨ ម៉ោង (ម៉ោងការងារ)**

ក្នុងករណីនេះ កម្មករនិយោជិតមិនបានទាមទារអំពីការកំណត់ចំនួនខោអាវឱ្យកម្មករនិយោជិតធ្វើច្រើនពេកនោះទេ គឺ គ្រាន់តែទាមទារឱ្យនិយោជកកំណត់ចំនួនសំរាប់៨ម៉ោងតែប៉ុណ្ណោះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកកំណត់ចំនួនខោអាវឱ្យកម្មករនិយោជិតធ្វើលើសពី៨ម៉ោងនេះ ជាការត្រឹមត្រូវឬទេ?

មាត្រា២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា *"សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក ។..."*

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារខាងលើនេះមានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ល្គិកណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមហេតុផល។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ២៩/០៥- កាងនឹង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦, លេខ ១១៦/០៧- ប្រ្តេន សាន់ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ និងលេខ ៧៩/០៨-ញូ មេក ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១*)។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញដូចក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗដែរ គឺនិយោជកមានសិទ្ធិកំណត់បរិមាណខោ

អាវឱ្យកម្មករនិយោជិតធ្វើ ដរាបណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមហេតុផល ។

យោងតាមមាត្រា ១០៨ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ចែងថា: "*ចំពោះការងារម៉ោការ ឬតាមបរិមាណផលិតផល ទោះធ្វើនៅរោងជាង ឬនៅលំនៅក៏ដោយ ប្រាក់ឈ្នួលត្រូវតែយ៉ាងណាឱ្យកម្មករនិយោជិត* ***<u>ដែលមានការប៉ិនប្រសប់មធ្យម ធ្វើការជាធម្មតាបានទទួលក្នុងថិរវេលាធ្វើការដដែល</u>*** *នូវប្រាក់ឈ្នួលយ៉ាងតិច ស្មើនឹងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានា ហើយដែលកំណត់សំរាប់កម្មករនិយោជិត* ។"

យោងតាមមាត្រា១៣៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា: "*ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ* ។"

យោងតាមមាត្រា១០៨ និង១៣៧ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវកំណត់ម៉ោងធ្វើការរបស់កម្មករនិយោជិត ទោះជាកម្មករនិយោជិតម៉ៅការ ឬតាមបរិមាណផលិតផល គឺមិនត្រូវលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ ។

ម្យ៉ាងវិញទៀត នៅក្នុងសំណុំរឿងលេខ ១៤/០៣-ដូស៊ីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*ជាគោលការណ៍ ក្រុមហ៊ុនត្រូវធ្វើការកំណត់ចំនួន(ទំហំ)ការងារឱ្យបានសមស្រប ដែលកម្មករនិយោជិតមានការប៉ិនប្រសប់មធ្យមអាចធ្វើការជាធម្មតាក្នុងរយៈពេល៨ម៉ោងក្នុងមួយថ្ងៃ អាចធ្វើសំរេចទៅបានដោយទុកឱ្យមានរយៈពេលសំរាកឱ្យបានសមស្រប* ។"

យោងប្រការ៤ នៃប្រកាសលេខ ៨០ ស្តីពីការធ្វើការបន្ថែមម៉ោង ក្រៅពីថិរវេលាធ្វើការធម្មតា ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ១៩៩៩ ចែងថា : "*<u>ការរៀបចំធ្វើការថែមម៉ោងនេះ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពោល គឺម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន មិនត្រូវបង្ខិតបង្ខំ ឬដាក់វិន័យផ្សេងៗ ចំពោះកម្មករនិយោជិត ដែលមិនស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងឡើយ</u>* ។"

នៅក្នុងករណីនេះ ការអនុវត្តបច្ចុប្បន្ន ក្រុមហ៊ុនកំណត់ចំនួនខោអាវឱ្យកម្មករនិយោជិតធ្វើជូនកាល៨ម៉ោង ហើយជូនកាលទៀត១០ម៉ោង ទៅ១២ម៉ោងស្ទើរតែរាល់ថ្ងៃក្នុងមួយសប្តាហ៍។ ហេតុនេះហើយ កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនកំណត់ត្រឹម៨ម៉ោងវិញ ព្រោះជួនកាលកម្មករនិយោជិតធ្វើមិនហើយ ក៏ត្រូវបង្ខំចិត្តធ្វើការលើស១០ម៉ោង ឬ ១២ ម៉ោង ។

យោងតាមប្រការ៤ នៃប្រកាសលេខ ៨០ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវកំណត់ម៉ោងធ្វើការបន្ថែមម៉ោងដោយមានការស្ម័គ្រចិត្តពីកម្មករនិយោជិត មិនអាចកំណត់ដោយបង្ខំបានឡើយ ។ (សូមមើលសេចក្តីបង្គាប់*លេខ ១០៧/០៨ - ស៊ីវ៉ាតិច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១, លេខ ១១៨/០៧ - ចា ឌីង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២* និងលេខ *២៣/០៧ - យ៉ុង មិន*

*ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៥)* ។

ក្នុងករណីនេះការចាត់ចែងរបស់ក្រុមហ៊ុនកំណត់ចំនួនខោអាវឱ្យកម្មករនិយោជិតធ្វើសមាមាត្រចំនួនលើសពី៨ម៉ោងនេះ មានលក្ខណៈមិនស្របច្បាប់ និងមិនសមហេតុផលទេ ពីព្រោះកម្មករនិយោជិតមិនស្ម័គ្រចិត្តធ្វើការលើសពី៨ម៉ោងឡើយ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យក្រុមហ៊ុនកំណត់ចំនួនខោអាវសំរាប់កម្មករ និយោជិតធ្វើការ៨ម៉ោងដាច់ដោយឡែក ដើម្បីធានាថា ការបន្ថែមម៉ោងធ្វើឡើងដោយស្ម័គ្រចិត្ត។ តែបើក្រុមហ៊ុនកំណត់លើសពី៨ម៉ោង ត្រូវមានការយល់ព្រមដោយស្ម័គ្រចិត្តពីកម្មករនិយោជិត។

**ចំណុចវិវាទទី ៧: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយសម្រាប់ការបន្ថែមម៉ោងពីម៉ោង ៦:០០ ដល់ម៉ោង ៨:៣០ ឱ្យបានទៀងទាត់រាល់ថ្ងៃ**

ក្នុងករណីនេះ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយសម្រាប់ការបន្ថែមម៉ោង ពីម៉ោង ៦:០០ ដល់ម៉ោង៨:៣០ឱ្យបានទៀងទាត់រាល់ថ្ងៃ។ និយោជកមិនអាចបើកឱ្យបានរាល់ថ្ងៃទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកត្រូវបើប្រាក់ថ្លៃបាយសម្រាប់ការបន្ថែមម៉ោងពីម៉ោង៦:០០ ដល់ម៉ោង ៨:៣០ ឱ្យបានទៀងទាត់រាល់ថ្ងៃ ឬទេ?

យោងតាមមាត្រា១០៣ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា: " ...***មិនត្រូវរាប់បញ្ចូលជាមួយប្រាក់ឈ្នួល*** *:... អត្ថប្រយោជន៍ដែលផ្តល់ឱ្យជាពិសេសចំពោះកម្មករនិយោជិតដើម្បីសំរួលការបំពេញមុខងារ*"

យោងតាមអង្គហេតុ កម្មករនិយោជិតទទួលបានប្រាក់ថ្លៃបាយបន្ថែម ១០០០ រៀលទៀត នៅពេលធ្វើការបន្ថែមម៉ោងបន្តពីម៉ោង០៦:០០ រហូតដល់ម៉ោង០៨:៣០ ដោយនិយោជកបានព្រមព្រៀងផ្តល់ឱ្យ។ យោងតាមមាត្រា១០៣ នៃច្បាប់ស្តីពីការងារខាងលើនេះ ប្រាក់ថ្លៃបាយបន្ថែមចំនួន១០០០រៀលទៀតនេះ មិនមែនជាផ្នែកនៃប្រាក់ឈ្នួលឡើយ គឺជាប្រាក់អត្ថប្រយោជន៍ដែលផ្តល់ឱ្យជាពិសេសចំពោះកម្មករនិយោជិត ដើម្បីសំរួលការបំពេញមុខងារ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានច្បាប់ណាកំណត់ពីរបៀបបើកប្រាក់នេះឡើយ ។

ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរចែងពីការបើកប្រាក់ថ្លៃបាយបន្ថែមចំនួន១០០០រៀលពេលកម្មករនិយោជិតធ្វើការថែមម៉ោងបន្តពីម៉ោង០៦:០០ រហូតដល់ម៉ោង ០៨:៣០ ទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកបើកប្រាក់ថ្លៃបាយបន្ថែមសម្រាប់ការបន្ថែមម៉ោង ពីម៉ោង ៦:០០ ដល់ម៉ោង៨:៣០ឱ្យបានទៀងទាត់រាល់ថ្ងៃ។

ដោយសំអាងលើអង្គហេតុ ភស្តុតាង និងអង្គច្បាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ២ និងទី៨ :**

បដិសេធពិចារណាការទាមទារឱ្យក្រុមហ៊ុនទទួលយកលោក រៃ ណាំ ដែលជាលេខាសហជីព សម្ព័ន្ធកម្មករកម្ពុជាចូលធ្វើការវិញ និងបដិសេធការទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការគម្រាមកំហែងចំពោះកម្មករ ដែលមានប្រាក់ជំនាញ និងបិទសិទ្ធិសេរីភាពរបស់ពួកគេ។

**ចំណុចវិវាទទី ៣ :**

បង្គាប់ឱ្យក្រុមហ៊ុនកំណត់ចំនួនខោអាវសំរាប់កម្មករនិយោជិតធ្វើ៨ម៉ោងដាច់ដោយឡែក ដើម្បីធានាថា ការបន្ថែមម៉ោងធ្វើឡើងដោយស្ម័គ្រចិត្ត។ តែបើក្រុមហ៊ុនកំណត់លើសពី៨ម៉ោង ត្រូវមានការយល់ព្រមដោយស្ម័គ្រចិត្តពីកម្មករនិយោជិត។

**ចំណុចវិវាទទី ៧:**

បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកបើកប្រាក់ថ្លៃបាយសម្រាប់ការបន្ថែមម៉ោងពីម៉ោង ៦:០០ ដល់ម៉ោង ៨:៣០ ឱ្យបានទៀងទាត់រាល់ថ្ងៃ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុំ សុទ្ធី**

ហត្ថលេខា: -----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អេន ណាន**

ហត្ថលេខា: -----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: -----------------------------------